# ព្រះរាជក្រម

នស/រកម/១២១៣/០១៨

**យើង**

**ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី**
**សមានភូមិជាតិសាសនា រត្តនខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ**
**ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា**
**ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី**

- បានទ្រង់យល់រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រមលេខ ជស/រកម/០៤៩៨/០៦ ចុះថ្ងៃទី០៨ ខែមេសា ឆ្នាំ១៩៩៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃក្រុមប្រឹក្សាធម្មនុញ្ញ
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០១០៧/០០៥ ចុះថ្ងៃទី៣១ ខែមករា ឆ្នាំ២០០៧ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីវិសោធនកម្មច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃក្រុមប្រឹក្សាធម្មនុញ្ញ
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយរបស់សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា

## ប្រកាសឲ្យប្រើ

ច្បាប់ ស្តីពីការបង្កើតក្រសួងឧស្សាហកម្ម និងសិប្បកម្ម ដែលរដ្ឋសភាបានអនុម័ត កាលពីថ្ងៃទី១២ ខែវិច្ឆិកា ឆ្នាំ២០១៣ នាសម័យប្រជុំរដ្ឋសភាលើកទី១ នីតិកាលទី៥ ហើយដែលព្រឹទ្ធសភាបានពិនិត្យចប់សព្វគ្រប់លើទម្រង់ និងគតិច្បាប់នេះទាំងស្រុង កាលពីថ្ងៃទី២១ ខែវិច្ឆិកា ឆ្នាំ២០១៣ នាសម័យប្រជុំវិសាមញ្ញ នីតិកាលទី៣ ព្រមទាំងត្រូវបានក្រុមប្រឹក្សាធម្មនុញ្ញប្រកាសថាស្របនឹងរដ្ឋធម្មនុញ្ញ ក្នុងសេចក្តីសម្រេចលេខ១៤៨/០១៩/២០១៣ កបធ.ច ចុះថ្ងៃទី០៣ ខែធ្នូ ឆ្នាំ២០១៣ ហើយដែលមានសេចក្តីទាំងស្រុងដូចតទៅ៖



ROYAUME DU CAMBODGE

# ច្បាប់
# ស្តីពី
# ការបង្កើតក្រសួងឧស្សាហកម្ម និងសិប្បកម្ម

**មាត្រា ១.-**

ត្រូវបានបង្កើតក្រសួងឧស្សាហកម្ម និងសិប្បកម្ម ចំណុះរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា ។

**មាត្រា ២.-**

ក្រសួងឧស្សាហកម្ម និងសិប្បកម្ម មានសមត្ថកិច្ចដឹកនាំនិងគ្រប់គ្រងវិស័យឧស្សាហកម្មនិងសិប្បកម្ម នៃព្រះរាជាណាចក្រកម្ពុជា។

**មាត្រា ៣.-**

ក្រសួងឧស្សាហកម្មនិងសិប្បកម្ម ត្រូវបានដឹកនាំដោយរដ្ឋមន្ត្រីមួយរូប ដែលអមដោយរដ្ឋលេខាធិការ និង/ឬអនុរដ្ឋលេខាធិការតាមការចាំបាច់ ។

**មាត្រា ៤.-**

ការរៀបចំរចនាសម្ព័ន្ធ និងការប្រព្រឹត្តទៅរបស់ក្រសួងឧស្សាហកម្មនិងសិប្បកម្ម ត្រូវកំណត់ដោយអនុក្រឹត្យ ។

**មាត្រា ៥.-**

វិស័យឧស្សាហកម្មនិងសិប្បកម្ម ដែលជាសមត្ថកិច្ចរបស់ក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល ពីមុន ត្រូវស្ថិតនៅក្រោមក្រសួងឧស្សាហកម្មនិងសិប្បកម្ម ។

ច្បាប់និងលិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធនឹងវិស័យឧស្សាហកម្ម រ៉ែ និងថាមពល ដែលនៅជាធរមាន ត្រូវមានអានុភាពអនុវត្តបន្ត រហូតដល់មានការកំណត់ជាថ្មី ដោយអនុលោមតាមបទប្បញ្ញត្តិនៃច្បាប់នេះ ។

ROYAUME DU CAMBODGE
LE MINISTRE DU PALAIS ROYAL

រដ្ឋមន្ត្រីនិងរដ្ឋលេខាធិការក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល ដែលត្រូវបានតែងតាំងដោយព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី ២៤ ខែ កញ្ញា ឆ្នាំ ២០១៣ ត្រូវបន្តដឹកនាំនិងគ្រប់គ្រងក្រសួងឧស្សាហកម្មនិងសិប្បកម្ម រហូតដល់មានការតែងតាំងរដ្ឋមន្ត្រីនិងរដ្ឋលេខាធិការក្រសួងឧស្សាហកម្មនិងសិប្បកម្ម ។

**មាត្រា ៦.–**

ច្បាប់ស្តីពីការបង្កើតក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល ដែលត្រូវបានប្រកាសឲ្យប្រើដោយព្រះរាជក្រមលេខ នស/រកម/០១៩៦/០៥ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ និងបទប្បញ្ញត្តិទាំងឡាយដែលផ្ទុយនឹងច្បាប់នេះត្រូវទុកជានិរាករណ៍ ។

**មាត្រា ៧.–**

ច្បាប់នេះ ត្រូវបានប្រកាសជាការប្រញាប់ ។

ធ្វើនៅព្រះបរមរាជវាំង ថ្ងៃទី ០៦ ខែ ធ្នូ ឆ្នាំ ២០១៣

ពរស.១២១៣.១២៥៥

**ព្រះហស្តលេខា និងព្រះរាជលញ្ឆករ**
**នរោត្តម សីហមុនី**

បានយកសេចក្តីក្រាបបង្គំទូលថ្វាយព្រះមហាក្សត្រ
សូមឡាយព្រះហស្តលេខា
**នាយករដ្ឋមន្ត្រី**
**ហត្ថលេខា**
**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

លេខ: ១៣១៥ស.ណ
**សំណៅចំលងតាមច្បាប់ដើម សម្រាប់ជាការចែកផ្សាយ**
**រាជធានីភ្នំពេញ ថ្ងៃទី ១៦ ខែ ធ្នូ ឆ្នាំ២០១៣**
**អគ្គលេខាធិការរាជរដ្ឋាភិបាល**
**សយ សុខា**